ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ១១៦៧ សជណ.ករ

រាជធានីភ្នំពេញថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
សូមជម្រាបជូន
ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**កម្មវត្ថុ** : ករណីសំណើសូមគោរពអនុញ្ញាតជាគោលការណ៍ជូនក្រុមហ៊ុន ប៉េ ឌូច អភិវឌ្ឍន៍ គ្រុប ឌូអិលធីឌី ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ និងចិញ្ចឹមសត្វ លើផ្ទៃដីសរុបចំនួន ៣៥០ហិកតា រយៈពេល៧០ឆ្នាំ ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ។

**យោង** : -លិខិតលេខ១០៨៣សណ ប.ស្ថ.អគជ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ របស់ក្រសួងបរិស្ថាន
-ចំណារសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានយល់ព្រមអនុញ្ញាតជាគោលការណ៍ជូនក្រុមហ៊ុន ប៉េ ឌូច អភិវឌ្ឍន៍ គ្រុប ឌូអិលធីឌី ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ និងចិញ្ចឹមសត្វ លើផ្ទៃដីសរុបចំនួន៣៥០ហិកតា (បីរយហាសិបហិកតា) រយៈពេល៧០ ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ ដែលស្ថិតនៅខាងក្រៅតំបន់វិនិយោគឥណទានការបោន ដូចមានផែនទី និងនិយាមការជូនភ្ជាប់មកជាមួយ។

ក្នុងកិច្ចដំណើរការវិនិយោគអភិវឌ្ឍន៍នេះ ក្រសួងបរិស្ថានរួមជាមួយអាជ្ញាធរដែនដី និងក្រុមហ៊ុនត្រូវធ្វើការសិក្សារៀបចំប្លង់មេ កំណត់តំបន់ត្រូវអភិវឌ្ឍន៍ដាំដំណាំកសិ-ឧស្សាហកម្ម ដាំដំណាំកៅស៊ូ និងចិញ្ចឹមសត្វដោយកំណត់មិនឲ្យប៉ះពាល់ដល់ដីលំនៅឋាន ភូមិករ ស្រែចំការស្របច្បាប់របស់ប្រជាពលរដ្ឋ និងត្រូវកំណត់តំបន់នេះទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងអនុវត្តស្របតាមនីតិវិធី នៃច្បាប់ជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ម៉ៅ ហាស់ ណាស់

**ចម្លងជូន:**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រះវិហារ
- ក្រុមហ៊ុន ប៉េ ឌូច អភិវឌ្ឍន៍ គ្រុប ឌូអិលធីឌី
- ឯកសារ-កាលប្បវត្តិ

19/12/2011